**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## នាឱកាសពិធីបុណ្យទន្លេលើកទី២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ
## ថ្ងៃទី១១-១៣ ខែមីនា ឆ្នាំ២០១៦

******

- *ជនរួមជាតិទាំងអស់ជាទីមេត្រី !*

ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវការវិវឌ្ឍយ៉ាងច្រើនទាំងក្នុងទិដ្ឋភាព នយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម។ តាមរយៈនយោបាយឈ្នះ-ឈ្នះ កម្ពុជាបានផ្លាស់ប្តូររូបភាពយ៉ាងឆាប់រហ័សពីអ្វីដែលគេធ្លាប់ស្គាល់ថាជាទឹកដីនៃវាលពិឃាត ទឹកដីសង្គ្រាម សំបូរដោយគ្រាប់មីនមក ជាកម្ពុជាមួយដែលមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាពពេញលេញ និងមានការអភិវឌ្ឍរីកចំរើនលើគ្រប់វិស័យ ប្រកបដោយក្តីសង្ឃឹមឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងនិងត្រចះត្រចង់។

ក្នុងស្មារតីឆ្លើយតបទៅនឹងនិន្នាការនៃការអភិវឌ្ឍនេះ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាព ដើរតួនាទីជា «មាសបៃតង» រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈការបង្កើតនិងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់និងប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ជាពិសេសចូលរួមដល់ការឆ្លើយតបនឹងបំរែបំរួលអាកាសធាតុ ដែលជាបញ្ហាប្រឈមជាសាកល។

ទន្ទឹមនឹងនេះ ភាពសម្បូរបែបនៃសក្តានុពលទេសចរណ៍តាមដងទន្លេ បាននិងកំពុងរួមចំណែកធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយឧត្តមភាពនិងភាពទាក់ទាញខ្ពស់ ព្រមទាំងចូលរួមចំណែកសម្រេចចក្ខុវិស័យអាស៊ានជាគោលដៅទេសចរណ៍លំដាប់ថ្នាក់ពិភពលោក និងប្រកបដោយភាពកក់ក្តៅ «ASEAN: the World-Class Destination» និង «ASEAN: Feels the Warmth» ស្របពេលដែលទេសចរណ៍តាមដងទន្លេ ជាពិសេសទេសចរណ៍មេគង្គ បានក្លាយជាផលិតផលទេសចរណ៍សំខាន់មួយសម្រាប់កម្ពុជា ក៏ដូចជាតំបន់អាស៊ាន។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានសម្រេចឱ្យមានការប្រារព្ធ **ពិធីបុណ្យទន្លេ** ឡើងជារៀងរាល់ឆ្នាំ ដែលនេះគឺជាព្រឹត្តិការណ៍ទេសចរណ៍ថ្មីមួយទៀតសម្រាប់កម្ពុជា ដែលមិនត្រឹមតែចូលរួមចំណែកដល់ការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍នៃខេត្តជាប់ដងទន្លេរបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍតំបន់តាមដងទន្លេប្រកបដោយនិរន្តរភាព

និងការទទួលខុសត្រូវ ជាពិសេសការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការការពារ និងអភិរក្សធនធានធម្មជាតិ ដោយឈរលើការប្តេជ្ញាចិត្តរួមមួយច្បាស់លាស់ សំដៅរក្សាឱ្យបាននូវតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច សង្គមបរិស្ថាន និងវប្បធម៌របស់ប្រជាពលរដ្ឋមូលដ្ឋាន ដូចដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈប្រធានបទនៃពិធីបុណ្យទន្លេលើកទី២នេះគឺ «ទន្លេស្អាត សហគមន៍ល្អ»។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍នេះក៏ជាឱកាសមួយដើម្បីពង្រឹងគុណភាព សេវាកម្ម ការបង្កើត និងការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ប្រកបដោយការច្នៃប្រឌិតខ្ពស់ ជាពិសេសទេសចរណ៍តាមនាវា និងសហគមន៍ទេសចរណ៍តាមដងទន្លេ ព្រមទាំងរួមចំណែកជំរុញការតភ្ជាប់រឹតចំណងមិត្តភាព សាមគ្គីភាពរវាងបណ្តាប្រទេសក្នុងតំបន់អាស៊ាន ជាពិសេសពង្រឹងភាពជាដៃគូក្នុងក្របខណ្ឌមហាអនុតំបន់មេគង្គ។

ឆ្លៀតក្នុងឱកាសពិធីដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បងប្អូនជនរួមជាតិទាំងអស់ និងវិស័យឯកជន ចូលរួមឱ្យបានផុសផុលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យពិធីបុណ្យទន្លេលើកទី២ឆ្នាំនេះ និងពិធីបុណ្យទន្លេជាបន្តបន្ទាប់ ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ។ លើសពីនេះទៀត ខ្ញុំក៏សូមអំពាវនាវដល់ប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរជាតិនិងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងបងប្អូនប្រជាពលរដ្ឋ ចូលរួមសហការថែរក្សាសោភ័ណភាព អនាម័យ បរិស្ថាន ដែលជាកត្តាចម្បងមិនអាចខ្វះបានក្នុងការថែរក្សាសោភ័ណភាពខេត្តតាមដងទន្លេឱ្យកាន់តែស្រស់ស្អាត គង់វង្សយូរអង្វែង ដើម្បីទុកជាមរតកដល់កូនចៅជំនាន់ក្រោយ។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការប្រារព្ធពិធីបុណ្យទន្លេនឹងក្លាយជាកាលានុវត្តភាពដ៏ប្រសើរថ្មីមួយទៀតក្នុងការធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ចូលរួមចំណែកក្នុងការបង្កើនប្រាក់ចំណូល ការបង្កើតនិងបង្កើនការងារ សំដៅកាត់បន្ថយភាពក្រីក្រជូនដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ជាពិសេសចូលរួមចំណែកក្នុងការសម្រេចឱ្យបាននូវ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ និងរបស់កម្ពុជា ព្រមទាំងបង្កើនស្មារតីស្រឡាញ់ជាតិមាតុភូមិ សាមគ្គីភាព និងមិត្តភាពផងដែរ។ ចំពោះមុខនេះ ខ្ញុំសូមជូនពរឱ្យការប្រារព្ធ ពិធីបុណ្យទន្លេឆ្នាំ២០១៦ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងប្រកបដោយភាពសប្បាយរីករាយ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ខែមីនា ឆ្នាំ២០១៦

**ហ៊ុន សែន**